រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ១២៤៩ ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០០៩

# ប្រកាស
## ស្តីពី
## កិច្ចប្រជុំចូលកាន់តំណែង កិច្ចប្រជុំសាមញ្ញលើកទី១ កិច្ចប្រជុំសាមញ្ញលើកទី២របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការប្រកាសចូលកាន់តំណែងនៃគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី១ និងការទទួលខុសត្រូវបន្តនូវសិទ្ធិ និងការទទួលខុសត្រូវពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី២ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ របស់ គ.ជ.អ.ប

# សម្រេច

**ប្រការ ១.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំចូលកាន់តំណែងក្នុងរយៈពេលមិនលើសពីដប់បួន(១៤)ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត។

កាលបរិច្ឆេទជាក់ស្តែងនៃកិច្ចប្រជុំចូលកាន់តំណែងនៃក្រុមប្រឹក្សានីមួយៗ នឹងកំណត់តាមលិខិតដោយឡែករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ ២.-**

សមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលំដាប់លេខរៀងទី១ នៃបញ្ជីបេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេក្នុងក្រុមប្រឹក្សា ជាអ្នកធ្វើលិខិតកោះអញ្ជើញសមាជិកក្រុមប្រឹក្សា ដែលជាប់ឆ្នោតក្នុងក្រុមប្រឹក្សារបស់ខ្លួន ឱ្យចូលប្រជុំក្នុងកិច្ចប្រជុំចូលកាន់តំណែងតាមការកំណត់ដូចមានចែងក្នុងប្រការ១នៃប្រកាសនេះ។

ក្នុងកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សានីមួយៗ ត្រូវអញ្ជើញសមាសភាពមួយចំនួនចូលរួមជាកិត្តិយស និងជាសាក្សីផង។

សមាសភាពភ្ញៀវដែលត្រូវអញ្ជើញចូលរួម មានក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងមុខតំណែង ត្រូវរៀបចំទីកន្លែងប្រជុំ និងជួយធ្វើជាលេខាធិការក្នុងការចាត់ចែងកិច្ចប្រជុំនេះ។

**ប្រការ ៣.-**

កិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពមន្ត្រីមួយរូប ដែលចាត់តាំងដោយសេចក្តីសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

កិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពមន្ត្រីមួយរូប ដែលចាត់តាំងដោយអភិបាលរាជធានី ខេត្ត។

**ប្រការ ៤.-**

គណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី១នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រកាសឱ្យចូលកាន់តំណែងរួមគ្នាជាមួយកិច្ចប្រជុំចូលកាន់តំណែងនៃក្រុមប្រឹក្សារបស់ខ្លួន។

**ប្រការ ៥.-**

អធិបតីនៃកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សាអាណត្តិទី១ ត្រូវសម្របសម្រួលកិច្ចប្រជុំតាមកម្មវិធីដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ ៦.-**

ក្នុងកិច្ចប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សាអាណត្តិទី១ ត្រូវរៀបចំឱ្យមានការចុះហត្ថលេខាលើកំណត់ហេតុប្រគល់ ទទួលសិទ្ធិ និងការទទួលខុសត្រូវ រវាងអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ជាមួយក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១ ដែលមានប្រធានក្រុមប្រឹក្សាជាតំណាង ។

គំរូនៃកំណត់ហេតុប្រគល់ ទទួលខាងលើនេះ មានក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ ។

**ប្រការ ៧.-**

ក្នុងការទទួលសិទ្ធិ និងការទទួលខុសត្រូវបន្តពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្ន ចាប់ពីថ្ងៃ ប្រកាសចូលកាន់តំណែងរបស់ខ្លួន គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវបន្តចាត់ចែងប្រចាំថ្ងៃនូវសិទ្ធិ និងការទទួលខុសត្រូវទាំងអស់ រួមទាំងដីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀងការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់កាសទាំងអស់ដែលអនុវត្ត ឬដែលបានកាន់កាប់ដោយ ឬក្នុងនាមរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងអង្គភាព និងមន្ត្រី បុគ្គលិកទាំងអស់ដែលបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មុនការប្រកាសចូលកាន់តំណែង ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

ក្នុងការចាត់ចែងការងារប្រចាំថ្ងៃ គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ដោយត្រូវធានាឱ្យបាននូវនិរន្តរភាពការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ៨.-**

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញលើកទី១ មិនឱ្យហួសពីដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីថ្ងៃប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សា ។

ប្រធានក្រុមប្រឹក្សាត្រូវកំណត់កាលបរិច្ឆេទ និងកោះអញ្ជើញសម្រាប់កិច្ចប្រជុំសាមញ្ញលើកទី១របស់ខ្លួន ។

កូរ៉ុមនៃកិច្ចប្រជុំសាមញ្ញលើកទី១ ត្រូវមានសមាជិកអញ្ជើញចូលរួមប្រជុំលើសពីពាក់កណ្ដាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល គឺ :

- ក្រុមប្រឹក្សាមានសមាជិក ២១ រូប ត្រូវមានសមាជិកយ៉ាងតិច ១១ រូប
- ក្រុមប្រឹក្សាមានសមាជិក ១៩ រូប ត្រូវមានសមាជិកយ៉ាងតិច ១០ រូប
- ក្រុមប្រឹក្សាមានសមាជិក ១៧ រូប ត្រូវមានសមាជិកយ៉ាងតិច ០៩ រូប
- ក្រុមប្រឹក្សាមានសមាជិក ១៥ រូប ត្រូវមានសមាជិកយ៉ាងតិច ០៨ រូប
- ក្រុមប្រឹក្សាមានសមាជិក ១៣ រូប ត្រូវមានសមាជិកយ៉ាងតិច ០៧ រូប
- ក្រុមប្រឹក្សាមានសមាជិក ១១ រូប ត្រូវមានសមាជិកយ៉ាងតិច ០៦ រូប
- ក្រុមប្រឹក្សាមានសមាជិក ០៩ រូប ត្រូវមានសមាជិកយ៉ាងតិច ០៥ រូប

**ប្រការ ៩.-**

កិច្ចប្រជុំសាមញ្ញលើកទី១របស់ក្រុមប្រឹក្សា គឺជាកិច្ចប្រជុំផ្សព្វផ្សាយ និងស្តាប់របាយការណ៍លើបញ្ហា ដូចខាងក្រោម :-

**ទីមួយ** : ការផ្សព្វផ្សាយអំពីសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា និងគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវថតចម្លងឯកសារនេះជូនគ្រប់សមាជិកក្រុមប្រឹក្សាដោយភ្ជាប់ជាមួយលិខិតអញ្ជើញប្រជុំ។

**ទីពីរ :** ការផ្តួចផ្តើមរៀបចំសេចក្តីព្រាងប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាសម្រាប់រយៈពេលដប់ពីរ (១២)ខែ ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២។

**ទីបី :** អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីស្ថានភាពនៃការទទួលបន្តអនុវត្តការងារនៃរដ្ឋបាលរបស់ខ្លួន ចាប់ពីថ្ងៃចូលកាន់តំណែងរហូតមកដល់កិច្ចប្រជុំសាមញ្ញលើកទី១នេះ។

**ទីបួន :** បញ្ហាផ្សេងៗ។

ក្រុមប្រឹក្សាមិនត្រូវអនុម័តបញ្ហាណាមួយក្នុងកិច្ចប្រជុំសាមញ្ញលើកទី១នេះឡើយ។

**ប្រការ ១០.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន មិនឱ្យមុនម្ភៃប្រាំ(២៥)ថ្ងៃ ឬលើសពីសាមសិបប្រាំ(៣៥)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១ឡើយ។

**ប្រការ ១១.-**

ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២របស់ខ្លួន ក្រុមប្រឹក្សាត្រូវអនុម័តឱ្យបាននូវឯកសារដូចខាងក្រោម :-

- ដីកាស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន
- ប្រតិទិននៃកិច្ចប្រជុំសាមញ្ញសម្រាប់រយៈពេលដប់ពីរ(១២)ខែ រាប់ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២នេះទៅ
- ផែនការសកម្មភាពរបស់ខ្លួនរយៈពេលបី(០៣)ខែ ចាប់ពីកិច្ចប្រជុំសាមញ្ញលើកទី២នេះទៅ។

**ប្រការ ១២.-**

ដើម្បីធានាដល់ការចាប់ផ្តើមបំពេញការងាររបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន បន្ទាប់ពីការប្រកាសចូលកាន់តំណែង អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវ :-

**១**-ចាត់តាំងមន្ត្រីសមស្របនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន ឱ្យទទួលភារកិច្ចបន្ថែមក្នុងការធ្វើជាលេខាធិការក្រុមប្រឹក្សារបស់ខ្លួន រហូតដល់មានការរៀបចំជាថ្មី។

មន្ត្រីដែលទទួលជាលេខាធិការក្រុមប្រឹក្សាមានភារកិច្ច :-

- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំឱ្យដល់អ្នកដែលត្រូវអញ្ជើញចូលរួមប្រជុំ
- រៀបចំទីកន្លែងប្រជុំ

– រៀបចំសេចក្ដីព្រាងកំណត់ហេតុនៃកិច្ចប្រជុំ ជូនក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័ត

– រៀបចំ តាក់តែងឯកសារនានា តាមតម្រូវការរបស់ក្រុមប្រឹក្សា

– ទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា

**២**- បែងចែកភារកិច្ចជូនអភិបាលរងនានាតាមសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**៣**- សម្របសម្រួលការងារប្រចាំថ្ងៃក្នុងរដ្ឋបាលរបស់ខ្លួន ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**៤**- រៀបចំសេចក្ដីព្រាងផែនការសកម្មភាពរយៈពេល០៣ខែរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួន ពិនិត្យ ពិភាក្សា និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ។

ផែនការសកម្មភាពនេះ ត្រូវឆ្លុះបញ្ចាំងអំពីការងារសំខាន់ៗ ដូចខាងក្រោម :-

– ការអនុវត្តផែនការ កម្មវិធី គម្រោង និងការងារនានាបន្តពីរដ្ឋបាលបច្ចុប្បន្ន

– ការអនុវត្តផែនការ កម្មវិធី គម្រោង និងការងារថ្មីៗតាមតម្រូវការនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

– ការងារផ្សេងៗទៀតតាមតម្រូវការ និងលទ្ធភាពនៃធនធានដែលមាន ។

**ប្រការ ១៣.–**

ចំណាយទាំងអស់សម្រាប់កិច្ចប្រជុំ និងការបំពេញការងារនៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាបន្ទុកនៃថវិការដ្ឋបាលរាជធានី ខេត្ត ក្នុងពេលដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនទាន់មានថវិកាផ្ទាល់របស់ខ្លួន ។

**ប្រការ ១៤.–**

ក្នុងពេលពុំទាន់មានប្រព័ន្ធទំនាក់ទំនង និងការគាំទ្ររដ្ឋបាលក្រុង ស្រុក ខណ្ឌតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី និងអភិបាលខេត្ត ត្រូវបានប្រគល់សិទ្ធិធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងការភ្ជាប់ទំនាក់ទំនង និងការគាំទ្រនានាពីថ្នាក់ជាតិទៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងដែនដីរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

ប្រព័ន្ធគាំទ្រឃុំ សង្កាត់ត្រូវបន្តអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លេខ១៨៨៤ ប្រ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្ត ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ រហូតដល់មានលិខិតបទដ្ឋានថ្មីមកជំនួស ។

អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនអំពីសកម្មភាពគាំទ្រខាងលើនេះ រៀងរាល់កិច្ចប្រជុំសាមញ្ញនៃក្រុមប្រឹក្សា ឬតាមតម្រូវការចាំបាច់នៃក្រុមប្រឹក្សារបស់ខ្លួន ។

**ប្រការ ១៥.–**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយកនៃអគ្គនាយក

ដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*(ដើម្បីជូនជ្រាប)*

- *ដូចប្រការ ១៥*

*(ដើម្បីអនុវត្ត)*

- *ឯកសារ កាលប្បវត្តិ*

ឧបសម្ព័ន្ធទី១

## សមាសភាពភ្ញៀវ ដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទី១

| ល.រ | សមាសភាពភ្ញៀវ | ក្រុមប្រឹក្សា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | រាជធានី | ខេត្ត | ក្រុង | ស្រុក | ខណ្ឌ | |
| ១ | អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងមុខតំណែង | x | x | x | x | x | |
| ២ | ប្រធានមន្ទីរ អង្គភាពជំនាញនៃក្រសួង ស្ថាប័ននានា ប្រចាំនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | x | x | x | x | x | |
| ៣ | មេឃុំ ចៅសង្កាត់ | x | 0 | x | x | x | |
| ៤ | សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត | x | x | 0 | 0 | 0 | |
| ៥ | ប្រធានអង្គភាពកងយោធពលខេមរភូមិន្ទ នគរបាល កងរាជអាវុធហត្ថប្រចាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | x | x | x | x | x | |
| ៦ | តំណាងសភាពាណិជ្ជកម្ម | x | x | 0 | 0 | 0 | |
| ៧ | តំណាងអង្គការជាតិ និងអន្តរជាតិដែលមាននៅក្នុង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមការចាំបាច់ | x | x | x | x | x | |
| ៨ | តំណាងគណបក្សដែលមានអាសនៈក្នុងក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | x | x | x | x | x | |

កំណត់សម្គាល់ :

- សញ្ញា “x” ជាសញ្ញាដែលត្រូវអញ្ជើញចូលរួមប្រជុំ
- សញ្ញា “0” ជាសញ្ញាបញ្ជាក់មិនបាច់អញ្ជើញចូលរួមប្រជុំ

ឧបសម្ព័ន្ធទី២

## កម្មវិធីប្រជុំចូលកាន់តំណែង
## ក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១

១. ចុះបញ្ជីវត្តមានសម្រាប់តែសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត ដែលបានអញ្ជើញចូលរួមប្រជុំចូលកាន់តំណែង ។

២. គណៈចាត់តាំងកម្មវិធីប្រកាសកម្មវិធី និងជម្រាបជូនអំពីគណៈអធិបតី ភ្ញៀវកិត្តិយស ។

៣. គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៤. អានឈ្មោះប្រធានក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត និងជម្រាបជូនអំពីវត្តមានជាក់ស្តែង និងមូលហេតុសមាជិកដែលអវត្តមាន (ប្រសិនបើមាន) ។ ក្នុងពេលអានឈ្មោះសមាជិកណាម្នាក់ សមាជិកនោះគួរក្រោកឈរដើម្បីបង្ហាញខ្លួនដល់អង្គពិធី ។

៥. អានព្រះរាជក្រឹត្យ និងអនុក្រឹត្យពីការតែងតាំងគណៈអភិបាលសម្រាប់អាណត្តិទី១នៃក្រុមប្រឹក្សា

៦. ពិធីចុះហត្ថលេខាប្រគល់ ទទួលការងាររវាងអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបញ្ចប់ការងារ និងប្រធានក្រុមប្រឹក្សាអាណត្តិទី១ ក្នុងនាមក្រុមប្រឹក្សា និងគណៈអភិបាលអាណត្តិទី១ ។

៧. មតិចាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាអាណត្តិទី១ ក្នុងនាមក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

៨. មតិផ្តាំផ្ញើរបស់អធិបតីនៃអង្គប្រជុំ ។

ឧបសម្ព័ន្ធទី៣

# កំណត់ហេតុស្តីពី
# ការប្រគល់សិទ្ធិ និងការទទួលខុសត្រូវ
# ពីរដ្ឋបាល..........បច្ចុប្បន្ន ទៅក្រុមប្រឹក្សា និងគណៈអភិបាល..........អាណត្តិទី១
# តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ឆ្នាំពីរពាន់ប្រាំបួន ខែ........ថ្ងៃទី..........

**១**-យើងអភិបាល......*(រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)*....... ជាតំណាងឱ្យរដ្ឋបាល..........*(រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)*.......... ដែលបញ្ចប់អាណត្តិតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សូមផ្ទេរសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវស្របច្បាប់ទាំងអស់នៃរដ្ឋបាល................. ជូនទៅក្រុមប្រឹក្សាអាណត្តិទី១ និងគណៈអភិបាលរបស់ខ្លួនចាប់ពីថ្ងៃនេះ ដើម្បីទទួលខុសត្រូវចាត់ចែងបន្ត ស្របតាមមាត្រា២៧៧ មាត្រា២៨០ មាត្រា២៨១ និងមាត្រា២៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**២**-យើងជាតំណាងឱ្យក្រុមប្រឹក្សាអាណត្តិទី១ ដែលកើតចេញពីការបោះឆ្នោតនាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ និងជាតំណាងឱ្យគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី១នេះ នឹងបន្តអនុវត្តនូវសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវស្របច្បាប់ទាំងអស់ នៃរដ្ឋបាល.......*(រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)*......... ដើម្បីចាត់ចែងស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**៣**-កំណត់ហេតុនេះ ធ្វើឡើងក្នុងកិច្ចប្រជុំចូលកាន់តំណែងនៃក្រុមប្រឹក្សាអាណត្តិទី១ នាថ្ងៃទី........ ខែ............ ឆ្នាំ២០០៩ នៅចំពោះមុខសាក្សីជាភ្ញៀវទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ ។

**តំណាងក្រុមប្រឹក្សាអាណត្តិទី១ និងគណៈអភិបាល**
**សម្រាប់អាណត្តិទី១នៃក្រុមប្រឹក្សា**
**ប្រធានក្រុមប្រឹក្សា**
(ហត្ថលេខា និងឈ្មោះ)

**តំណាងរដ្ឋបាល...............**
**អភិបាល..........**
(ហត្ថលេខា និងឈ្មោះ)

កំណត់សម្គាល់ :

- អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យរៀបចំឡើងវិញនូវកំណត់ហេតុ ដោយផ្អែកតាមខ្លឹមសារក្នុងគំរូខាងលើនេះ ។
- ក្នុងការរៀបចំឡើងវិញនេះ ត្រូវដាក់ឈ្មោះជាក់ស្តែងនៃរដ្ឋបាលរបស់ខ្លួន :

  ឧទាហរណ៍ :

  - រដ្ឋបាលរាជធានីភ្នំពេញ
  - រដ្ឋបាលខេត្តតាកែវ
  - រដ្ឋបាលស្រុកអូរជ្រៅ
  - រដ្ឋបាលក្រុងចិត្របូរី... ។ល ។
- កំណត់ហេតុនេះត្រូវធ្វើជា ០៣ច្បាប់ ក្នុងនោះ :
  - សម្រាប់រាជធានី ខេត្ត : រក្សាទុក០២ច្បាប់នៅសាលារាជធានី ខេត្តរបស់ខ្លួន និង០១ច្បាប់ផ្ញើមកក្រសួងមហាផ្ទៃ ។
  - សម្រាប់ក្រុង ស្រុក ខណ្ឌ : រក្សាទុក០២ច្បាប់នៅសាលាក្រុង ស្រុក ខណ្ឌរបស់ខ្លួន និង០១ច្បាប់ផ្ញើមកសាលារាជធានី សាលាខេត្តសាមី ។